# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងបរិស្ថាន**

លេខ: ៤៧៤ សជណ.ប.ស្ត

## សេចក្តីប្រកាសព័ត៌មាន

អនុលោមតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥ និងការកែទម្រង់ស៊ីជម្រៅក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ ជាពិសេសស្មារតីនៃវេទិកាថ្នាក់ជាតិលើកទី២ ស្តីពី **«ការការពារ និងអភិរក្សធនធានធម្មជាតិ»** ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្រសួងបរិស្ថានបាននឹងកំពុងសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការរៀបចំអនុវត្តគម្រោងចុះបញ្ជីដីរដ្ឋ សម្រាប់តំបន់ការពារធម្មជាតិចំនួនពីរកន្លែង ពោលគឺ «ដែនជម្រកសត្វព្រៃពាមក្រសោប» ស្ថិតក្នុងភូមិសាស្ត្រខេត្តកោះកុង និង «ដែនជម្រកសត្វព្រៃភ្នំព្រេច» ស្ថិតក្នុងភូមិសាស្ត្រខេត្តមណ្ឌលគិរី ដែលគ្របដណ្តប់លើផ្ទៃដីសរុបចំនួន ២៦៤.២៥០ ហិកតា (ពីរសែនប្រាំមួយម៉ឺនបួនពាន់ពីររយហាសិបហិកតា)។ គម្រោងនេះ គឺជាគម្រោងសាកល្បងចុះបញ្ជីដីរដ្ឋលើកដំបូង ដែលទទួលបានការគាំទ្រផ្នែកថវិកាពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ចំនួន ១,២៥ លានដុល្លារសហរដ្ឋអាមេរិក ក្រោមគម្រោងរបៀងអភិរក្សជីវៈចម្រុះមហាអនុតំបន់មេគង្គ ដើម្បីធានាប្រសិទ្ធភាពគ្រប់គ្រងដែនជម្រកសត្វព្រៃទាំងពីរ ដោយកំណត់ច្បាស់លាស់នូវព្រំប្រទល់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ជាពិសេសតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ ក៏ដូចជាព្រំប្រទល់ដែនជម្រកសត្វព្រៃទាំងមូល។

ការចុះបញ្ជីដីរដ្ឋ សម្រាប់តំបន់ការពារធម្មជាតិ គឺជាយុទ្ធសាស្ត្រថ្មីមួយ ដើម្បីពង្រឹងប្រសិទ្ធភាពគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិនៅកម្ពុជា ដែលមានវិសាលភាពគ្របដណ្តប់លើផ្ទៃដីសរុបប្រមាណ ៧,៥ លានហិកតា ស្មើនឹងប្រមាណ ៤១% នៃផ្ទៃដីប្រទេសកម្ពុជា ហើយទន្ទឹមនឹងនេះ ឈានទៅលុបបំបាត់ទាំងស្រុងនូវករណីទំនាស់ដីធ្លីក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

គម្រោងសាកល្បងចុះបញ្ជីដីរដ្ឋ នឹងចាប់ផ្តើមសកម្មភាពជាក់ស្តែងនៅតាមតំបន់គោលដៅក្នុងពេលឆាប់ៗខាងមុខនេះ ដោយត្រូវចុះធ្វើការពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធ ដើម្បីធានាថា ដំណើរការចុះបញ្ជីដីរដ្ឋសម្រាប់ដែនជម្រកទាំងពីរប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលដូចការរំពឹងទុក។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ២០១៧

អាគារមរតកតេជោ ដីឡូលេខ503 ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

# ផែនទីកំណត់តំបន់គ្រប់គ្រងដែនជម្រកសត្វព្រៃភ្នំព្រេច ស្ថិតក្នុងខេត្តមណ្ឌលគិរី

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ២០១៧







Map Coordinate System:
Unit: meter
System: UTM, Zone 48
Datum: WGS 1984

0 7.5 15 km

សញ្ញាសម្គាល់
- ទីរួមខេត្ត
- ទីតាំងភូមិ
- ព្រំប្រទល់ខេត្ត
- តំបន់ស្នូល
- តំបន់អភិរក្ស
- តំបន់ប្រើប្រាស់ដោយនិរន្តរភាព
- តំបន់សហគមន៍
- ព្រំប្រទល់ដែនជម្រកសត្វព្រៃភ្នំព្រេច

គម្របព្រៃឈើ ឆ្នាំ២០១៨
- ព្រៃស្រោង
- ព្រៃល្បោះ
- ព្រៃឫស្សី
- ដំណាំកសិកម្ម
- ទំនាប
- ភូមិ
- ដំណាំឧស្សាហកម្ម
- វាលស្មៅ

ផ្ទៃដីដែនជម្រកសត្វព្រៃភ្នំព្រេច ទំហំសរុប ២២២៥០០ ហិកតា

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៨

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់


281 ha
283 ha
3.961 ha
1.024 ha
912 ha
Study Village
Road
Settlement
Core Zone 1.588 ha
Conservation Zone 4.873 ha
Community Zone 4.023 ha
Sustainable Use Zone 15.413 ha
Peam Krasop Wildlife Sanctuary
0 0.5 1 2 Km
Coordinate System: UTM
Unit: Metter
Datum: Indian 1960
Zone: 48 N